ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តសៀមរាប**

លេខ: ០៤៨/១៦ សសរ

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ៤៩៧២
មកដល់ថ្ងៃទី២៤ ខែ០៦ ឆ្នាំ១៦
ម៉ោង ១០:៣០

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តសៀមរាប

## អភិបាល នៃគណៈអភិបាលខេត្ត

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រមលេខ នស.រកម ០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៨៤ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប។

-យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ២០១៦ របស់ក្រសួងមុខងារសាធារណៈ។

## សម្រេច

**ប្រការ១**.-ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងគោលបំណងសម្របសម្រួលការអនុវត្តកម្មវិធីជាតិ យុទ្ធសាស្ត្រ និង សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តសៀមរាប។

**ប្រការ២**.-ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៃរដ្ឋបាលខេត្តសៀមរាប មានសមាសភាពដូចខាងក្រោម ៖

១.លោក លី សំរិទ្ធ អភិបាលរងខេត្ត ប្រធាន
២.លោក នួន សុខុម ប្រធានមន្ទីរមុខងារសាធារណៈ អនុប្រធានអចិន្ត្រៃយ៍
៣.លោក នួន ពុទ្ធារ៉ា នាយករដ្ឋបាលសាលាខេត្ត សមាជិក
៤.លោក ណម ពិសិដ្ឋ ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
៥.លោក ចាន់ ភត្រា ប្រធានរតនាគារខេត្ត សមាជិក
៦.លោក អភិបាលក្រុង.ស្រុក គ្រប់ស្រុក សមាជិក
៧.លោក គង់ គឹមសាយ អនុប្រធានមន្ទីរមុខងារសាធារណៈ សមាជិក
៩.លោក ស្មៀន ប៊ុនធឿន នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត សមាជិក
៨.លោក ង៉ែត ឫក្ស ប្រធានការិ.ក្របខណ្ឌនិងបណ្តុះបណ្តាលនៃមន្ទីរមុខងារសាធារណៈ លេខាធិការ
៩.លោក រុន ណារ៉េត ប្រធានការិ.ត្រួតពិនិត្យរដ្ឋបាលនិងបៀវត្សនៃមន្ទីរមុខងារសាធារណៈ លេខាធិការ។

**ប្រការ៣**.-ក្រុមការងារនេះ មានតួនាទី ភារកិច្ច និង ការទទួលខុសត្រូវ ដូចខាងក្រោម ៖

-សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈនៃរដ្ឋបាលខេត្តសៀមរាប ជាមួយក្រសួង.ស្ថាប័នថ្នាក់ជាតិ

-សហការសម្របសម្រួល ជាមួយ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥.២០១៨

-រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ប្រចាំត្រីមាស ជូនក្រសួង.ស្ថាប័នថ្នាក់ជាតិ គណៈអភិបាល និង ក្រុមប្រឹក្សាខេត្ត

-ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារ តាមការអញ្ជើញរបស់ប្រធានក្រុមការងារ

-មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់មន្ទីរ.អង្គភាពសាមីក្នុងករណីចាំបាច់ ដើម្បីគាំទ្រដល់ការបំពេញបេសកកម្មរបស់ក្រុមការងារ។

**ប្រការ៤**.- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥**.- នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ.អង្គភាពនានាជុំវិញខេត្ត អភិបាលក្រុង ស្រុក និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

សៀមរាប,ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**ឃឹម_ប៊ុនសុង**

__កន្លែងទទួល__ ៖

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-រតនាគារជាតិ

-លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

-ក្រុមប្រឹក្សាខេត្ត

«*__ដើម្បីគោរពជូនជ្រាប__*»

-ដូចប្រការ៥

«*__ដើម្បីសហការអនុវត្ត__*»

-ឯកសារ.កាលប្បវត្តិ